រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ
# មហាសន្និបាតភាគហ៊ុនិកលើកទី៤

**ក/.កាលបរិច្ឆេទ** ៖ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ចាប់ពីម៉ោង៨:០០ព្រឹក

**ខ/.ទីកន្លែង** ៖ សាលប្រជុំរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

**គ/.សមាសភាពចូលរួម៖**

- គណៈអធិបតី ៖ ១. ឯកឧត្តម សឹម ណារ៉ា ប្រធានក្រុមប្រឹក្សាភិបាល
  ២. ឯកឧត្តម ស៊ឹម ស៊ីថា អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
  ៣. លោកស្រី ធិន ចន្ទ្រា សមាជិកក្រុមប្រឹក្សាភិបាល - តំណាងនិយោជិត
  ៤. លោកឧកញ៉ា ចាង យុនហ្វេង សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន
  ៥. លោក អោម សេងបូរ៉ា សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលឯករាជ្យ
- ភ្ញៀវកិត្តិយស ៖ ១. លោក តន់ សុខជា តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម
  ២. លោក ជូ វណ្ណៈ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  ៣. លោក លឹម ចាន់ណា តំណាងគណៈកម្មការមូលបត្រកម្ពុជា
  ៤. លោក Tang Limchhoung តំណាងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
  ៥. លោក ស៊ីយ៉ា ម៉ាលីដា តំណាងធនាគារអេស៊ីលីដា ភីអិលស៊ី ។
- លេខាកត់ត្រា ៖ លោកបណ្ឌិត ជា វិសុទ្ធ អគ្គនាយករងទទួលបន្ទុកជាលេខាសហគ្រាស និង លោក ហួត សុខហេង នាយលេខាធិការដ្ឋាន។
- អ្នកចូលរួម ៖ ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះនៅភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ រ.ទ.ស.ភ (ធនាគារអេស៊ីលីដា ភីអិលស៊ី) ដើម្បីត្រៀមចូលរួមមហាសន្និបាតមានចំនួន៦០នាក់ គិតជាភាគហ៊ុនមានចំនួន ៧៦.១១១.២៣៧ហ៊ុន ស្មើនឹង៨៨%នៃភាគហ៊ុនធម្មតាសរុប។ ភាគហ៊ុនិកដែលបានចុះវត្តមាននិងបានចូលរួមមហាសន្និបាតជាក់ស្តែងមានចំនួន៥១នាក់ គិតជាភាគហ៊ុនមានចំនួន៧៥.៧០៣.៨១១ហ៊ុន (ស្មើនឹង៩៩%នៃចំនួនភាគហ៊ុនដែលបានចុះឈ្មោះចូលរួម) ក្នុងនោះលោក ជូ វណ្ណៈ អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាអាណត្តិគាហកៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ឃ/.ដំណើរការនៃមហាសន្និបាត**

## ១/.បទបង្ហាញស្តីពីលទ្ធផលអាជីវកម្មឆ្នាំ២០១៥ និងទិសដៅអាជីវកម្មឆ្នាំ២០១៦

លោក រស់ គឹមលាង អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ចនិងផ្សារមូលបត្រ បានធ្វើរបាយការណ៍ជូនអង្គមហាសន្និបាតជ្រាបពីលទ្ធផលអាជីវកម្មឆ្នាំ២០១៥ និងទិសដៅអាជីវកម្មឆ្នាំ២០១៦ តាមរយៈការបញ្ចាំងស្លាយជាភាសាខ្មែរ និងភាសាអង់គ្លេស ដោយមានគោលខ្លឹមសារសំខាន់ៗ ដូចមានក្នុងឯកសារសម្រាប់មហាសន្និបាត។ លោកក៏បានធ្វើការកត់សម្គាល់ផងដែរថា ៖

- ជារួម ក្នុងឆ្នាំ២០១៥ រ.ទ.ស.ភ ផលិតទឹកស្អាតសរុប១៦៣.១៤៩.១០០ម៣, ដាក់បំពង់ចែកចាយបានប្រវែង១៤៣គ.ម និងបានកាត់បន្ថយអត្រាទឹកបាត់បង់ពី៧,៧៦% ក្នុងឆ្នាំ២០១៤ មកនៅត្រឹម៥,៩៩%។ ទន្ទឹមគ្នានោះ តបណ្តាញជូន អតិថិជនបានចំនួន១៨.២១២បណ្តាញ ក្នុងនោះអតិថិជនបន្ទប់ជួលមានចំនួន៤.៦០៣បណ្តាញ ដែល ទទួលបានការអនុគ្រោះលើថ្លៃប្រើប្រាស់ទឹក គឺ១.០៣០រៀល/ម៣ ដោយអនុវត្តតាមការអំពាវនាវរបស់ រាជរដ្ឋាភិបាល និងអតិថិជនចំណូលទាបមានចំនួន៨៨៧បណ្តាញ។ អត្រាប្រមូលប្រាក់ថ្លៃទឹកអនុវត្តបាន៩៩,៩៣%។ ក្រៅពីនេះ ចំណូលសរុបប្រចាំឆ្នាំ គឺប្រមាណ១៩១,៣ ពាន់លានរៀល កើនលើសឆ្នាំ២០១៤ ប្រមាណ២២% ដែលជាហេតុធ្វើឱ្យប្រាក់ចំណេញពិតកើនលើសឆ្នាំកន្លងទៅ ២៤%។ ជាមួយកំណើនប្រាក់ចំណេញនេះ រ.ទ.ស.ភ បានបង្កើនមូលធនពី៧៣៦ពាន់លានរៀលក្នុងឆ្នាំ២០១៤ រហូតដល់ជិត៧៨៤ពាន់លានរៀល ក្នុងឆ្នាំ២០១៥។
- បណ្តាសន្ទស្សន៍សំខាន់ៗដែលសម្រេចបានក្នុងឆ្នាំ២០១៥ គឺ៖

| | | |
|---|---|---|
| ១. | អនុបាតចរន្ត | ៥,២២ ដង |
| ២. | អត្រាអនុបាតចរន្តលឿន | ៤,៣៩ ដង |
| ៣. | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ៤,៧៣% |
| ៤. | ផលចំណេញក្នុងមួយឯកតាមូលធន | ៧,៤៩% |
| ៥. | ចំណេញក្នុងមួយឯកតាកម្មសិទ្ធិ | ៦៥៤,៧៩ រៀល |
| ៦. | ភាគលាភក្នុងមួយឯកតាកម្មសិទ្ធិ | ១៥២,៥៧ រៀល |

- ទិសដៅសំខាន់ៗនៃអាជីវកម្មក្នុងឆ្នាំ២០១៦ គឺ៖

| | | |
|---|---|---|
| ១. | តបណ្តាញចូលផ្ទះថ្មីចំនួន | ១៦.០០០ បណ្តាញ |
| ២. | ចំនួនអតិថិជនចុងគ្រានាដំណាច់ឆ្នាំ២០១៦ | ៣០៤.០០០ បណ្តាញ |
| ៣. | បរិមាណទឹកលក់ | ១៥៨.៦០២.៦៨២ ម៣ |
| ៤. | បរិមាណទឹកផលិត | ១៧២.៣៩៤.២០០ ម៣ |
| ៥. | អត្រាធ្វើវិក្កយបត្រ | ៩២,០០% |
| ៦. | អត្រាទារប្រាក់ | ៩៩,៩០% |
| ៧. | ថ្លៃទឹកលក់ជាមធ្យម/ម៣ | ១.០២៥ រៀល |
| ៨. | ចំណូលសរុប | ១៨៣.៤៤០.២៦៧.៨០០ រៀល |
| ៩. | ចំណាយសរុប | ១៣៩.៣៤៩.៧០៣.០០០ រៀល |
| ១០. | ចំណេញពិត | ៤៥.៥៨៤.៥៥៤.០០០ រៀល។ |

- រ.ទ.ស.ភ គ្រោងនឹងពង្រីកសមត្ថភាពផលិតបន្ថែម តាមរយៈគម្រោងចំនួន២គឺ៖

(១) គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតចំការមន សមត្ថភាពផលិត៥២.០០០ម៣/ថ្ងៃ ដោយប្រើប្រាស់ហិរញ្ញប្បទានផ្ទាល់ពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)

(២) គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតព្រែកតាសេកសមត្ថភាពផលិត១៣០.០០០ម៣/ថ្ងៃ ដែលនឹងបញ្ជូនទឹកទៅផ្គត់ផ្គង់តំបន់នៅប៉ែកខាងលិចរាជធានីភ្នំពេញ។

## ២/. សំណួរ-ចម្លើយ

(គ្មាន)

## ៣/. មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ

ឯកឧត្តមប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈអធិបតីភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងភាគហ៊ុនិកទាំងអស់ ដែលបានអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី៤។

តាងនាមថ្នាក់ដឹកនាំ រ.ទ.ស.ភ ឯកឧត្តមបានគូសបញ្ជាក់ថា គោលបំណងនៃមហាសន្និបាតនេះ គឺដើម្បីពិនិត្យមើលលទ្ធផលអាជីវកម្មដែល រ.ទ.ស.ភ សម្រេចបានក្នុងឆ្នាំ២០១៥ និងទិសដៅអនុវត្តឆ្នាំ២០១៦ ដូចអ្វីដែលលោក រស់ គឹមលាង បានពន្យល់យ៉ាងក្បោះក្បាយក្នុងបទបង្ហាញ។

ឯកឧត្តមបានបញ្ជាក់បន្ថែមថា ក្នុងឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលបានដំណើរការប្រជុំចំនួន៦លើក ដោយយកចិត្តទុកដាក់ខ្ពស់ទៅលើសកម្មភាពអាជីវកម្ម និងធ្វើការគិតគូរវែងឆ្ងាយទៅលើការវិនិយោគ ជាពិសេសគម្រោងវិនិយោគសាងសង់រោងចក្រផលិតទឹកស្អាតព្រែកតាសេក ដែលជារោងចក្រធំមួយមានសមត្ថភាពផលិត ១៣០.០០០ម៣/ថ្ងៃ ស្មើនឹងប្រមាណ ៣០% នៃសមត្ថភាពផលិតទឹកបច្ចុប្បន្ន។ ហេតុដូច្នេះ ការគិតគូរពីអនាគត គឺជាយុទ្ធសាស្ត្រវែងឆ្ងាយរបស់ រ.ទ.ស.ភ ក្នុងការពង្រីកវិសាលភាពសេវាផ្គត់ផ្គង់ទឹកស្អាត ដើម្បីឆ្លើយតបតម្រូវការទឹកស្អាតរបស់ប្រជាពលរដ្ឋទាំងនៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ។ ជាមួយគ្នានោះដែរ ក្រុមប្រឹក្សាភិបាលនឹងពិនិត្យមើលសេវាផ្សេងៗទៀត ដើម្បីឱ្យ រ.ទ.ស.ភ អាចពង្រីកវិសាលភាពអាជីវកម្មរបស់ខ្លួន និងរកចំណូលបន្ថែម ដូចជាសេវាដាក់បំពង់ដែលធ្លាប់បានអនុវត្តក្រោមគម្រោងរបស់អង្គការ JICA ក្នុងខេត្តកំពង់ចាម និងខេត្តបាត់ដំបង។

ក្រៅពីនេះ ឯកឧត្តមក៏បានសង្កត់ធ្ងន់ទៅលើទិសដៅសំខាន់ៗមួយចំនួនរបស់ រ.ទ.ស.ភ គឺខិតខំបំពេញផ្ទៃសេវាទឹកស្អាតក្នុងរាជធានីភ្នំពេញឱ្យបាន១០០% ត្រឹមឆ្នាំ២០២០ ព្រមទាំងខិតខំរក្សាអត្រាដំណើរការសហគ្រាសឱ្យបានទាបជាង៤០%, អត្រាទារប្រាក់ថ្លៃទឹកមិនឱ្យទាបជាង៩៩%, អត្រាទឹកបាត់បង់ឱ្យស្ថិតក្នុងរង្វង់៥% និងថ្លៃលក់ទឹកជាមធ្យមក្នុងរង្វង់១.០០០រៀល/ម៣។

ជាកិច្ចបញ្ចប់នៃមហាសន្និបាត ឯកឧត្តមប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត បានថ្លែងអំណរគុណចំពោះគណៈអធិបតី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងសមាជិកនៃអង្គសន្និបាតទាំងមូល ដែលបានអញ្ជើញចូលរួម និងបានខិតខំបំពេញភារកិច្ចរបស់ខ្លួន ធ្វើឱ្យមហាសន្និបាតភាគហ៊ុនិកលើកទី៤របស់ រ.ទ.ស.ភ ប្រព្រឹត្តទៅដោយជោគជ័យ។

មហាសន្និបាតបានបញ្ចប់នាម៉ោង១០:០០នាទីព្រឹក នៃថ្ងៃនិងខែឆ្នាំដដែល។

**លេខាធិការសហគ្រាស**

បណ្ឌិត ជា វិសុទ្ធ

**ប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត**
**ប្រធានក្រុមប្រឹក្សាភិបាល**

សឹម_ណារ៉ា

__កន្លែងទទួល__ :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឯកឧត្តមប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- មន្ត្រីត្រួតពិនិត្យរដ្ឋអមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- គណៈកម្មការមូលបត្រកម្ពុជា

*"ដើម្បីជូនជ្រាប"*

- គ្រប់អង្គភាពចំណុះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

*"ដើម្បីមុខការ"*

- ឯកសារនិងកាលប្បវត្តិ។